**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តសៀមរាប**
**រដ្ឋបាលក្រុងសៀមរាប**

# កំណត់ហេតុ
# ស្តីពី
# កិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសតំណាងអាជីវករសម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋនៃរដ្ឋបាលក្រុងសៀមរាប

ពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបប្រាំពីរ បញ្ចស័ក ឆ្នាំថោះ ខែកត្តិក ៥កើត ថ្ងៃសុក្រ ត្រូវនឹងឆ្នាំពីរពាន់ម្ភៃបី ខែវិច្ឆិកា ថ្ងៃទីដប់ប្រាំពីរ វេលាម៉ោងប្រាំបី និងសូន្យៗនាទីព្រឹក នៅសាលប្រជុំរបស់រដ្ឋបាលក្រុងសៀមរាប បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយពីការជ្រើសរើសតំណាងអាជីវករសម្រាប់ធ្វើជា សមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ នៃរដ្ឋបាលក្រុងសៀមរាប ក្រោមអធិបតីភាព លោក **ទេព ប៊ុនឆាយ** ប្រធានក្រុមប្រឹក្សាក្រុង និងជាប្រធានអង្គប្រជុំ។

**ក - សមាសភាពអញ្ជើញចូលរួមកិច្ចប្រជុំ**

១-ប្រធានក្រុមប្រឹក្សាក្រុង ០១រូប
២-នាយករដ្ឋបាលចំនួន ០១រូប
៣-ប្រធានការិយាល័យ ០២រូប
៤-តំណាងអាជីវករ ២៥រូប
( ដូចមានបញ្ជីវត្តមានជូនភ្ជាប់ជាមួយ )

**ខ - កម្មវិធី**

១. មតិបើកកិច្ចប្រជុំ ដោយ លោក ទេព ប៊ុនឆាយ ប្រធានក្រុមប្រឹក្សាក្រុង
២. ការបង្ហាញពីនីតិវិធី និងលក្ខខណ្ឌនានា នៃការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ
   ២.១ ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋក្រុង
   ២.២ ការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង
   ២.៣ នីតិវិធី នៃការបោះឆ្នោតជ្រើសរើសតំណាងពីអាជីវករ ដើម្បីធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ។
៣. មតិបិទកិច្ចប្រជុំ ដោយ លោក ទេព ប៊ុនឆាយ ប្រធានក្រុមប្រឹក្សាក្រុង

**កម្មវិធីជាក់ស្តែង**

១- មតិបើកកិច្ចប្រជុំ ដោយ លោក ទេព ប៊ុនឆាយ ប្រធានក្រុមប្រឹក្សាក្រុង

ជាកិច្ចចាប់ផ្តើមលោក **ទេព ប៊ុនឆាយ** ប្រធានក្រុមប្រឹក្សាក្រុង និងជាប្រធានអង្គប្រជុំបានមានប្រសាសន៍ស្វាគមន៍ ចំពោះវត្តមាន លោកនាយករដ្ឋបាល លោក លោកស្រីប្រធានការិយាល័យ ព្រមទាំងលោក លោកស្រីតំណាងអាជីវកនានាក្នុងក្រុងសៀមរាប ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំនេះ។

បន្ទាប់មកលោកប្រធានក្រុមប្រឹក្សាក្រុង បានប្រកាសបើកកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសតំណាងអាជីវករសម្រាប់ធ្វើជា សមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ នៃរដ្ឋបាលក្រុងសៀមរាប ចាប់ពីពេលនេះតទៅ។

២. ការបង្ហាញពីនីតិវិធី និងលក្ខខណ្ឌនានា នៃការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

ជាកិច្ចបន្ត លោក **ឡំ សុខាក់** នាយករដ្ឋបាលសាលាក្រុង បានធ្វើបទបង្ហាញពីខ្លឹមសារ នីតិវិធី និងលក្ខខណ្ឌនានា នៃការជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋរួមមាន៖

របៀបវារៈទី១៖ អំពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យប្រជាពលរដ្ឋ ដោយលើកយកផ្នែកទី១ និងផ្នែកទី២ ក្នុងជំពូកទី៣ ចាប់ពីមាត្រា៣១ ដល់មាត្រា៣៨ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

របៀបវារៈទី២៖ ការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ដោយលើកយកនូវសេចក្តីណែនាំលេខ០៣៧ សណន ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ជូនអង្គប្រជុំ។

របៀបវារៈទី៣៖ បានលើកយកចំណុច១.៣.ការជ្រើសរើសតំណាងអាជីវករ នៃសេចក្តីណែនាំលេខ០៣៧ សណន ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ ស្តីពីការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ដោយបានលម្អិតម្តងមួយជំហានៗ និងបានសង្កត់ធ្ងន់លើសារៈសំខាន់ នៃការចូលរួមរបស់លោក លោកស្រី តំណាងអាជីវករ ក្នុងគ្រប់សកម្មភាពសំខាន់ៗ ចាប់ពីការចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ការចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដើម្បីសម្រេចបាននូវសមាសភាពតំណាងអាជីវករចំនួន៧រូប ធ្វើជាសមាជិក សមាជិកា នៃគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង។

៣. មតិបិទកិច្ចប្រជុំ ដោយ លោក ទេព ប៊ុនឆាយ ប្រធានក្រុមប្រឹក្សាក្រុង

ក្រោយពី លោក ឡំ សុខាក់ នាយករដ្ឋបាល បានធ្វើបទបង្ហាញនូវរបៀបវារៈទី១ ទី២ និងទី៣ រួចមក លោក ទេព ប៊ុនឆាយ ប្រធានក្រុមប្រឹក្សាក្រុង បានថ្លែងអំណរគុណដល់ លោក លោកស្រីសមាជិក សមាជិកា នៃអង្គប្រជុំ ដែលបានយកចិត្តទុកដាក់តាមដានស្តាប់ការបកស្រាយ និងការពន្យល់យ៉ាងក្បោះក្បាយរបស់លោកនាយករដ្ឋបាលសាលាក្រុង ព្រមទាំងបានកំណត់យកថ្ងៃទីម្ភៃម្ភៃបួន ខែវិច្ឆិកា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ដើម្បីប្រជុំបោះឆ្នោតជ្រើសរើសតំណាងអាជីវករសម្រាប់ ធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ហេតុដូចនេះសូមលោក លោកស្រី មេត្តាជ្រាប និងអញ្ជើញចូលរួមកុំបីខាន។ រដ្ឋបាលក្រុងនឹងចេញលិខិតអញ្ជើញតាមក្រោយឲ្យបានមុនថ្ងៃប្រជុំរយៈពេល៣ថ្ងៃ ដើម្បីឲ្យស្របតមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។

មុននឹងបញ្ចប់លោក ទេព ប៊ុនឆាយ ប្រធានក្រុមប្រឹក្សាក្រុង និងជាប្រធានអង្គប្រជុំ ក៏សូមថ្លែងអំណរគុណចំពោះវត្តមានលោក លោកស្រី ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយនេះ ហើយក៏សូមប្រសិទ្ធពរជ័យ សិរីមង្គលចូលមានដល់លោក លោកស្រី ទទួលបាននូវសុខភាពល្អ កំលាំងខ្លាំងក្លា ប្រាជ្ញាវាងវៃ ដើម្បីរួមចំណែកកសាងមាតុភូមិកម្ពុជារបស់យើង។

កិច្ចប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោងប្រាំបួន និងសាមសិបនាទី នាថ្ងៃខែឆ្នាំដដែល ក្នុងបរិយាកាសរីករាយស្និតស្នាល និងទទួលលទ្ធផលល្អប្រសើរ ស្របតាមផែនការដែលបានកំណត់។

លេខាកត់ត្រា

**បានឃើញ និង ឯកភាព**

**អធិបតីអង្គប្រជុំ**

សេព ប៊ុនឆាយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បញ្ជីវត្តមានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសតំណាងអាជីវករ**
**ធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ**
**នៃរដ្ឋបាលក្រុងសៀមរាប**

កាលបរិច្ឆេទ ថ្ងៃសុក្រ..៥កើត.. ខែកត្តិក.. ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០២៣

| ល.រ | គោត្តនាមនិងនាម | ភេទ | ឋានៈ និងតួនាទី | ស្ថាប័ន/អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| ១ | ហៀង ប៊ុនហួរ | ប្រុស | [illegible] | ក្រុងសៀមរាប | | |
| ២ | ហេង ចំរើន | ប្រុស | [illegible] | ក្រុងសៀមរាប | 017 405554 | |
| ៣ | ទី ស៊ីថើប | ស្រី | អាជីវករ | | | |
| ៤ | ផេង វិសាល | ស្រី | អាជីវករ | | | |
| ៥ | ភាំ មករា | ប្រុស | អាជីវករ | | 077 212668 | |
| ៦ | ហំ វិសាល | ប្រុស | អាជីវករ | | 012 617369 | |
| ៧ | ជឹង ចាន់ | ស្រី | —"— | | | |
| ៨ | ពៅ ថៃលា | ប្រុស | —"— | | | |
| ៩ | ឈៀប លីដា | ស្រី | អាជីវករ | | | |
| ១០ | សៀប វណ្ណៈ | ប្រុស | —"— | | | |
| ១១ | ចឹ សុភ័ម | ស្រី | —"— | | 0889988772 | |
| ១២ | លីម យាប់ | ប្រុស | —"— | | | |
| ១៣ | លឹម ចៅហ៊ី | ប្រុស | —"— | | 012952743 | |
| ១៤ | រស់ ម៉ារីង | ស្រី | —"— | | | |
| ១៥ | ជុំ ធារ់ណា | ស្រី | —"— | | | |
| ១៦ | សៅ ផាន៊ីប | ប្រុស | —"— | | | |
| ១៧ | ជិន្ន រតនា | ស្រី | —"— | | | |
| ១៨ | សាត សុរិទ្ធ | ប្រុស | —"— | | | |
| ១៩ | រ៉ាតី គីមស៊ុប | ប្រុស | —"— | | | |
| ២០ | សោភ សុប៉ុន | ប្រុស | —"— | | 0617838425 | |
| ២១ | សៀក សុហ៊ុក | ប្រុស | —"— | | | |
| ២២ | ឈាប សុភា | ប្រុស | —"— | | | |
| ២៣ | ហ៊ុក សាបុត្ត | ប្រុស | —"— | | | |
| ២៤ | ចាន់ សុវត្ថិ | ប្រុស | —"— | | | |
| ២៥ | ពារ ណៃស៊ុប | ស្រី | —"— | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២៦ | សាន់ ឃុនី | ស្រី | អាជីវករ | | | |
| ២៧ | កេត រ៉ា | ប្រុស | អាជីវករ | | | |
| ២៨ | | | | | | |
| ២៩ | | | | | | |
| ៣០ | | | | | | |
| ៣១ | | | | | | |
| ៣២ | | | | | | |
| ៣៣ | | | | | | |
| ៣៤ | | | | | | |
| ៣៥ | | | | | | |
| ៣៦ | | | | | | |
| ៣៧ | | | | | | |
| ៣៨ | | | | | | |
| ៣៩ | | | | | | |

សរុប ៖...................នាក់

វត្តមាន៖.................នាក់

អវត្តមាន៖..............នាក់